**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខ: ០១៤៩/២០ ក.អ.ជ

ថ្ងៃអង្គារ ១១កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០២០

# របាយការណ៍បូកសរុបលទ្ធផល នៃការអនុវត្តការងារឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ការពារនិងរក្សាបានយ៉ាងរឹងមាំនូវសន្តិភាព ស្ថិរភាពនយោបាយនិងសេដ្ឋកិច្ច សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សម្រេចបានជោគជ័យយ៉ាងធំធេង ក្នុងការអភិវឌ្ឍប្រទេសជាតិឲ្យមានការរីកចម្រើនលើគ្រប់វិស័យ ដែលបាននាំមកនូវភាពសម្បូរសប្បាយសម្រាប់ជីវភាពរស់នៅរបស់ប្រជាជន ហើយកិត្យានុភាពជាតិត្រូវបានលើកកម្ពស់ទាំងក្នុងតំបន់និងលើឆាកអន្តរជាតិ។ ដំណើរការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ត្រូវបានជំរុញយ៉ាងខ្លាំងក្លា ដើម្បីឈានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ ក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ និងឆ្នាំ២០៥០ ក្លាយជាប្រទេសដែលមានចំណូលខ្ពស់។

ក្រសួងអភិវឌ្ឍន៍ជនបទបានរួមចំណែកយ៉ាងសកម្មក្នុងសមត្ថកិច្ចរបស់ខ្លួន ស្របតាមគោលដៅនៃចក្ខុវិស័យតាមកម្មវិធីអភិវឌ្ឍជនបទចម្រុះ ធ្វើឲ្យសម្រេចបាននូវសមិទ្ធផលសំខាន់ៗថ្មីៗជាច្រើន ជំរុញឲ្យមានការផ្លាស់ប្តូរជីវភាពរស់នៅដោយផ្ទាល់របស់ប្រជាជនជនបទប្រកបដោយបរិយាបន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន។ ប្រជាជននៅតំបន់ជនបទ ក្រៅពីការធ្វើស្រែចំការសម្រាប់ទ្រទ្រង់ជីវភាពប្រចាំថ្ងៃ បានឆ្លៀតប្រកបមុខរបរសិប្បកម្ម ធ្វើអាជីវកម្មលក់ដូរ និងផ្តល់សេវាកម្មយកកម្រៃ ដើម្បីបង្កើនប្រាក់ចំណូលបន្ថែមក្នុងគ្រួសារ។ ជាងនេះទៅទៀត ជនបទបច្ចុប្បន្នមានលំនៅដ្ឋានសមរម្យ មានចរន្តអគ្គិសនី ទឹកស្អាត បង្គន់អនាម័យ ផ្លូវគមនាគមន៍ ប្រព័ន្ធព័ត៌មានវិទ្យាកាន់តែសម្បូរបែបដែលកំពុងនាំមកនូវរបៀបរស់នៅដែលមានលក្ខណៈកាន់តែស៊ីវិល័យប្រហាក់ប្រហែលនឹងទីប្រជុំជនដែរ។

ក្នុងអាណត្តិរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់យក **"ភាពចាំបាច់ក្នុងការបន្តលើកកម្ពស់គុណភាពនិងការថែទាំហេដ្ឋារចនាសម្ព័ន្ធជនបទ ការទទួលបានទឹកស្អាតប្រកបដោយសុវត្ថិភាព និងការជំរុញការលើកកម្ពស់អនាម័យជនបទ"** ជាទិសដៅចម្បងរបស់ខ្លួន សំដៅរួមចំណែកធ្វើឲ្យសម្រេចបាននូវ **"ការបន្តជំរុញការអភិវឌ្ឍជនបទឲ្យរស់រវើក ដោយបន្តវិនិយោគលើផ្លូវជនបទ ប្រព័ន្ធធារាសាស្ត្រខ្នាតតូច ការពង្រីកការគ្រប់ដណ្តប់ការប្រើប្រាស់អគ្គិសនី ការពង្រីកការទទួលបានទឹកស្អាត ការលើកកម្ពស់អនាម័យ ការរៀបចំភូមិនិងលំនៅដ្ឋាន ព្រមទាំងការលើកកម្ពស់ជីវភាពប្រជាជន តាមរយៈ**

**ការបន្តអនុវត្តចលនាភូមិមួយផលិតផលមួយ និងចលនាភូមិថ្មី"** ដែលមានចែងនៅចំណុចទី១០ មុំទី១ក្នុងចតុកោណទី៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល។

ក្នុងស្មារតីខាងលើនេះ ក្រសួងបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ២០១៩-២០២៣ ដោយផ្តោតជាសំខាន់លើ (១).ពង្រឹងស្ថាប័ន អភិវឌ្ឍសមត្ថភាព និងធនធានមនុស្ស, (២).អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងគមនាគមន៍, (៣).លើកកម្ពស់លក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ និង (៤).ធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចនៅតំបន់ជនបទ។

ក្នុងឆ្នាំ២០១៩កន្លងមកនេះ ក្រសួងសម្រេចបានលទ្ធផលជាច្រើន ដូចខាងក្រោម៖

## ១. ការពង្រឹងស្ថាប័ន អភិវឌ្ឍសមត្ថភាព និងធនធានមនុស្ស

ដើម្បីពង្រឹងស្ថាប័ន អភិវឌ្ឍសមត្ថភាព និងធនធានមនុស្ស ក្រសួងបានចាត់ទុកការលើកកម្ពស់អភិបាលកិច្ចល្អ អភិវឌ្ឍចំណេះដឹងជំនាញវិជ្ជាជីវៈមន្ត្រីរាជការ ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ សីលធម៌ មនសិការស្នេហាជាតិ ស្រឡាញ់វិជ្ជាជីវៈ និងស្មារតីទទួលខុសត្រូវ ព្រមទាំងអភិវឌ្ឍចំណេះដឹង ចំណេះធ្វើដល់ប្រជាជនជនបទ ជាគោលដៅអាទិភាពដែលមានការងារជាយុទ្ធវិធីសំខាន់ៗចំនួន០៣ រួមមាន (១).ការងារពង្រឹងស្ថាប័ន (២).ការងារបណ្តុះបណ្តាលមន្ត្រីរាជការ និង(៣).ការបណ្តុះបណ្តាលចំណេះដឹងចំណេះធ្វើដល់ប្រជាជនជនបទ។

### ១.១. ការពង្រឹងស្ថាប័ន

ក្រសួងអភិវឌ្ឍន៍ជនបទបានធ្វើកំណែទម្រង់ផ្ទៃក្នុងផង និងបានចូលរួមក្នុងដំណើរការអនុវត្តកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលផង រួមមាន៖

**ទី១.**យោងតាមភាពចាំបាច់របស់ក្រសួង ក្រុមការងារនីតិកម្មត្រូវបានបង្កើតឡើងតាមសេចក្តីសម្រេចលេខ ២៦៣/១៩ ក.អ.ជ-សសរ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីសិក្សាស្រាវជ្រាវកែសម្រួលលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់និងបង្កើតថ្មី ដែលមានលក្ខណៈគ្របដណ្តប់លើការងារជំនាញគ្រប់អង្គភាពសំដៅធ្វើឲ្យការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ២០១៩-២០២៣ ទទួលបានជោគជ័យ។ ជាលទ្ធផលឆ្នាំ២០១៩នេះក្រុមការងារបានពិនិត្យឯកសារគតិយុត្តចំនួន ០៣ ដើម្បីស្នើសុំធ្វើវិសោធនកម្ម រួមមាន (១).អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ (២).អនុក្រឹត្យលេខ ១៤១ អនក្រ.បក ចុះថ្ងៃទី៣១ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យ យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និង(៣).អនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើង។

ក្រៅពីនេះ ក្រសួងបានរៀបចំដាក់ឲ្យដំណើរការជាបណ្តោះអាសន្ននូវមន្ទីរពិសោធន៍ តាមរយៈសេចក្តីកំណត់លេខ ០៣២២/១៩ ន.ផ.ជ ស្តីពីរចនាសម្ព័ន្ធនិងភារកិច្ចមន្ទីរពិសោធន៍របស់ក្រសួងអភិវឌ្ឍន៍ជនបទ។ អង្គភាពពិសោធន៍នេះ បានទទួលយកមកធ្វើការពិសោធន៍នូវសំណាកកៅស៊ូក្រាលថ្មល់ បេតុង ដីស ក្រួសក្រហម ដែកសរសៃ ថ្មមិច បានចំនួន ១៣គម្រោង ពីបណ្តាមន្ទីរអភិវឌ្ឍន៍ជនបទចំនួន ១២ខេត្ត រួមមាន (១).ខេត្តឧត្តរមានជ័យ (២).ខេត្តស្ទឹងត្រែង (៣).ខេត្តកំពង់ឆ្នាំង (៤).ខេត្តកំពង់ធំ (៥).ខេត្តបន្ទាយមានជ័យ (៦).ខេត្តរតនគិរី (៧).ខេត្តប៉ៃលិន (៨).ខេត្តព្រះវិហារ (៩).ខេត្តមណ្ឌលគិរី (១០).ខេត្តបាត់ដំបង (១១).

ខេត្តសៀមរាប និង(១២).ខេត្តពោធិ៍សាត់។

**ទី២.**ដើម្បីអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ក្រសួងបានបង្កើតក្រុមការងារពិភាក្សានិងរៀបចំវិភាគមុខងារ និងថវិកាដើម្បីផ្ទេរទៅឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្របតាមអនុក្រឹត្យចំនួន ០៣ រួមមាន (១).អនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង, (២).អនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ និង(៣).អនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក។ ក្នុងឆ្នាំ២០១៩នេះ ក្រសួងបានសម្រេចផ្ទេរមុខងារចំនួន ០៣ ទៅឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមាន (១).មុខងារផ្តល់សេវាអនាម័យជនបទ គឺបំផុសឲ្យបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល និងការងារសាងសង់ ថែទាំ និងជួសជុលបង្គន់អនាម័យសាធារណៈ (២).មុខងារថែទាំ និងជួសជុលសំណង់ផ្គត់ផ្គង់ទឹកស្អាតជនបទគ្រប់ប្រភេទ និង(៣).មុខងារថែទាំផ្លូវជនបទជាលក្ខណៈប្រចាំ ចំពោះផ្លូវដែលតភ្ជាប់ពីភូមិទៅភូមិ និងផ្លូវក្នុងភូមិគ្រប់ប្រភេទ លើកលែងតែផ្លូវក្រាលកៅស៊ូ និងផ្លូវបេតុងចេញ។ ក្នុងការផ្ទេរមុខងារនេះ ក្រសួងបានធ្វើឡើងចំនួន០២លើក រួមមាន (១)ផ្ទេរដោយការធ្វើប្រតិភូកម្មទៅដល់ស្រុក ចំនួន២០គឺ ស្រុកកំពង់ត្រាច ស្រុកឈូក ស្រុកបន្ទាយមាស ស្រុកជុំគិរី ស្រុកមេមត់ ស្រុកត្បូងឃ្មុំ ស្រុកក្រូចឆ្មារ ស្រុកបសេដ្ឋ ស្រុកគងពិសី ស្រុកឱរ៉ាល់ ស្រុកថ្ពង ស្រុកឧត្តុង្គ ស្រុកពញាក្រែក ស្រុកតំបែរ ស្រុកអូរាំងឪ ស្រុករលាប្អៀរ ស្រុកសាមគ្គីមានជ័យ ស្រុកភ្នំស្រួច ស្រុកសំរោងទង និងស្រុកកំពង់ត្រឡាច និង(២)ក្រសួងបានផ្ទេរដោយប្រគល់នូវមុខងារទាំង ០៣ នោះ ទៅឲ្យដល់គ្រប់ក្រុង ស្រុក ខណ្ឌ ទាំង២០៣ នៅទូទាំងប្រទេស។ មុខងារទាំងនោះ មានលក្ខណៈជាជម្រើសសម្រាប់ការអនុវត្តបានទាំងស្ថាប័នថ្នាក់ជាតិនិងទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ។ រាល់ការលើកផែនការការងារការបណ្តុះបណ្តាលបទដ្ឋានបច្ចេកទេស និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃគឺស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួង ដែលមានឆន្ទានុសិទ្ធិចង្អុលបង្ហាញ ដាក់ទិសដៅឲ្យស្របតាមគោលនយោបាយ និងបទដ្ឋានបច្ចេកទេសជាធរមាន។ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសហការជាមួយមន្ត្រីជំនាញរបស់ក្រសួងទទួលយកមុខងារទាំងនេះទៅរៀបចំអនុវត្ត និងកៀរគរថវិកាពីប្រភពនានា សម្រេចឲ្យបានស្របតាមផែនការមេរបស់ក្រសួងដែលបានដាក់ចេញ។

**ទី៣.**ការកែទម្រង់ហិរញ្ញវត្ថុសាធារណៈនៅដំណាច់ត្រីមាសទី៣ ឆ្នាំ២០១៩នេះ ក្រសួងសម្រេចបាន ៩៩,៩០% ក្នុងនោះបានរៀបចំ និងអនុវត្តផែនការសកម្មភាពដំណាក់កាលទី៣ (MAP3) បានទាំងស្រុង ជាពិសេសការអនុវត្តកម្មវិធីគ្រប់គ្រងប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុ (FMIS) ផែនការយុទ្ធសាស្ត្រថវិកា ០៣ឆ្នាំរំកិល (BSP) និងផែនការថវិកាប្រចាំឆ្នាំ(PB) ស្របតាមសូចនាករ និងការវិភាជន៍ថវិកាដែលបានគ្រោងទុក និងឈានឆ្ពោះទៅសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល។

ក្រសួងបានរៀបចំផែនការវិនិយោគសាធារណៈបីឆ្នាំរំកិល (PIP) ២០២០-២០២២ បានចំនួន ៣២គម្រោង ក្នុងនោះគម្រោងស្នើសុំថ្មីមានចំនួន២៥គម្រោង និងគម្រោងកំពុងដំណើរការមានចំនួន ០៧ គម្រោង ដែលផ្តោតជាសំខាន់លើហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងគមនាគមន៍ ទឹកស្អាតនិងអនាម័យ ការអភិវឌ្ឍសហគមន៍ជនជាតិដើមភាគតិច ការអភិវឌ្ឍធនធានមនុស្ស និងសេដ្ឋកិច្ចសង្គមនៅតាមតំបន់ជនបទ។ ទន្ទឹមនេះ តាមសារាចរណែនាំរបស់រាជរដ្ឋាភិបាល ក្រសួងបានដាក់បញ្ចូលកញ្ចប់ថវិកាវិនិយោគសាធារណៈ



CP-

ទៅក្នុងផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល (BSP) និងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (PIP) ២០២០-២០២២។ នេះជាឆ្នាំដំបូងដែលរាជរដ្ឋាភិបាលបានដាក់បញ្ចូលរួមគ្នាក្នុងផែនការ រវាងថវិកាចរន្តនិងថវិកាវិនិយោគ និងចំពោះផែនការថវិកាតាមកម្មវិធីឆ្នាំ២០២០ ក្រសួងក៏បានរៀបចំរួចរាល់ដូចការគ្រោងទុកផងដែរ។

**ទី៤.**ចំពោះកំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីកសាងរដ្ឋបាលមួយឲ្យកាន់តែមានភាពឆ្លើយតប មានប្រសិទ្ធភាព ប្រសិទ្ធផល និងជំនឿទុកចិត្ត លើកកម្ពស់វប្បធម៌សេវាសាធារណៈ មានឆន្ទៈម្ចាស់ការ និងមនសិការវិជ្ជាជីវៈនោះ ក្រសួងបានខិតខំយកចិត្តទុកដាក់អភិវឌ្ឍសមត្ថភាព កែលម្អការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស តាមរយៈការជំរុញការអនុវត្តគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ជាពិសេសពង្រឹងការគ្រប់គ្រង និងចាត់ចែងការងារកែលម្អការគ្រប់គ្រងជំនាញ និងចំនួនមន្ត្រី ស្របតាមគោលការណ៍ច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងបទប្បញ្ញត្តិជាធរមាន ដែលក្នុងនោះ (១).បានបញ្ជូនមន្ត្រីរាជការចូលរួមវគ្គបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាលបានចំនួន០៣ លើក (២).បានដំឡើងឋានន្តរសក្តិនិងថ្នាក់ ដល់មន្ត្រីរាជការចំនួន ៤៨៣នាក់ (៣).បានខិតខំរៀបចំឯកសារបៀវត្ស និងបើកបៀវត្សជូនដល់មន្ត្រីរាជការចំនួន ០២ដង ក្នុង១ខែ (៤).បានចុះតាមដាន និងពង្រឹងវត្តមានមន្ត្រីរាជការនៅតាមអង្គភាពក្រោមឱវាទក្រសួង ស្របទៅតាមអនុក្រឹត្យលេខ ៥៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យា, អនុក្រឹត្យលេខ ២១៧ ស្តីពីរបបនៃការសុំច្បាប់ និងការអនុញ្ញាតច្បាប់ឈប់សម្រាកគ្រប់ប្រភេទរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និង(៥).បានចូលរួមសហការជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ធ្វើសមាហរណកម្មបុគ្គលិកថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ទី៥.**ការប្រែប្រួលអាកាសធាតុជាហានិភ័យមួយ ដែលក្រសួងកំពុងព្យាយាមរិះរកមធ្យោបាយ និងបច្ចេកវិទ្យាថ្មីៗ ដើម្បីទប់ស្កាត់ បន្សាំ និងកាត់បន្ថយហានិភ័យផ្សេងៗដែលកើតមានជាយថាហេតុ។ ក្នុងឆ្នាំ២០១៩នេះ ជាលទ្ធផលក្រសួងបានខិតខំសិក្សាស្រាវជ្រាវ តាក់តែង និងធ្វើបច្ចុប្បន្នភាពស្តង់ដារ និងបទដ្ឋានបច្ចេកទេសស្ថាបនា ជួសជុល និងថែទាំផ្លូវជនបទ និងសំណង់សិល្បការ្យដែលជាបច្ចេកវិទ្យាថ្មីសម្រាប់បន្សាំនឹងការប្រែប្រួលអាកាសធាតុបានប្រមាណ ៧០% ដែលគ្រោងនឹងបញ្ចប់សព្វគ្រប់នៅដំណាច់ឆមាសទី១ ឆ្នាំ២០២០ ខាងមុខនេះ។ បច្ចេកវិទ្យាថ្មីៗទាំងនោះ បានផ្តោតជាសំខាន់លើមូលដ្ឋាននៃការសិក្សាគម្រោង ការរៀបចំផែនការ ការគណនា និងបទដ្ឋាននៃការតាមដានត្រួតពិនិត្យគម្រោង មានលក្ខណៈជាស្តង់ដារសកលស្របតាមបរិបទកម្ពុជា។ ជាក់ស្តែង ក្រសួងបានរៀបចំសាងសង់គម្រោងផ្លូវក្រាលកៅស៊ូពីរជាន់ដែលធន់នឹងការប្រែប្រួលអាកាសធាតុ មានប្រវែង ៣,៦២គម និងបានដាំកូនឈើអមសងខាងផ្លូវជនបទតាមបណ្តារាជធានី ខេត្ត បានចំនួន ៨៨ ០០៤ ដើមទទួលបានជោគជ័យដូចការគ្រោងទុក។

**ទី៦.**ក្រសួងបានចុះធ្វើសវនកម្មពិនិត្យឯកសារនៃការអនុវត្តចំណូល-ចំណាយថវិការដ្ឋ ការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងសម្រាប់ការិយបរិច្ឆេទ២០១៨-២០១៩ និងចុះពិនិត្យជាក់ស្តែងការងារសាងសង់ ជួសជុលអណ្តូងទឹក និងសាងសង់បង្គន់អនាម័យដោយប្រើប្រាស់ថវិការដ្ឋនៅតាមមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្តចំនួន ២៥ ទូទាំងព្រះរាជាណាចក្រកម្ពុជា។

មន្ត្រីនៃអគ្គាធិការដ្ឋានបានចុះធ្វើអធិការកិច្ចលើដំណើរការរដ្ឋបាលតាមផែនការប្រចាំឆ្នាំ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ២៣ រួមមាន ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្ត

ឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ធំ។ បានចុះពិនិត្យ អង្កេត និងស្រាវជ្រាវ តាមពាក្យបណ្តឹងចំនួន ២ករណី នៅខេត្តព្រៃវែង និងខេត្តបន្ទាយមានជ័យ និងបានសហការជាមួយអាជ្ញាធរសវនកម្មជាតិចុះធ្វើសវនកម្ម ស្តីពីការគ្រប់គ្រង ថែទាំ និងជួសជុលផ្លូវជនបទរបស់ក្រសួងអភិវឌ្ឍន៍ជនបទប្រចាំឆ្នាំ២០១៨។

**ទី៧.**ដើម្បីលើកកម្ពស់សិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រី ក្រសួងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការផ្សព្វផ្សាយអំពីទស្សនៈយេនឌ័រ អនុសញ្ញាស៊ីដ និងការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងបុរសនៅតាមសហគមន៍ ដែលមានអ្នកចូលរួមចំនួន ៣៩០នាក់ (ស្រីចំនួន ១០១នាក់)។ បានបញ្ជ្រាបការយល់ដឹងអំពីតួនាទីរបស់ស្ត្រីដែលជាមាតា ជាប្រពន្ធជាទីស្រឡាញ់ និងជាមេផ្ទះដ៏ប៉ិនប្រសព្វ សម្រាប់លើកកម្ពស់សេដ្ឋកិច្ច កិត្តិយស និងភាពសម្បូរសប្បាយប្រកបដោយសុភមង្គលក្នុងគ្រួសារ។ ជាពិសេស ក្រុមការងារយេនឌ័រ បានរួមសហការជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រៀបចំបើកវគ្គសិក្ខាសាលាផ្សព្វផ្សាយស្តីពីជំងឺអេដស៍ កាមរោគ និងសុខភាពផ្លូវភេទ ដើម្បីកាត់បន្ថយការរីករាលដាលឬការចម្លងជំងឺអេដស៍ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ ជាពិសេសយុវវ័យ ដែលមានសមាសភាពចូលរួមសរុបចំនួន ៣៩៧នាក់ (ស្រីចំនួន ២០៥នាក់)។

**ទី៨.**ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការបំពេញការងារ របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ក្រសួងអភិវឌ្ឍន៍ជនបទបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវសេចក្តីណែនាំលេខ ០១សណន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាល ស្តីពីតួនាទីភារកិច្ច និងរបៀបរបបការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ដោយបានចាត់តាំងមន្ត្រីថ្នាក់អគ្គនាយករងឡើងសម្រាប់តំណាងក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីបំពេញរចនាសម្ព័ន្ធក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត។

ក្នុងតួនាទីជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពង់ឆ្នាំង ក្នុងឆ្នាំ២០១៩ នេះ ក្រុមការងារសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់រួមមាន៖ (១).បានសហការជាមួយគណៈអភិបាលខេត្តកំពង់ឆ្នាំង រៀបចំបែងចែកនិងបំពេញបន្ថែមសមាសភាពចុះបេសកកម្មតាមក្រុង ស្រុក និងឃុំ សង្កាត់តាមការចាំបាច់ (២).បានបង្កើតលេខាធិការដ្ឋានដែលមានអភិបាលខេត្តជាប្រធាន និងមានសមាសភាពមកពីតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ មន្ត្រីមួយចំនួនពីសាលាខេត្ត និងពីមន្ទីរជំនាញនានា ដែលបានបូកសរុបលទ្ធផលការងារ និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលបានទៀងទាត់និងទាន់ពេលវេលា (៣).បានសហការរៀបចំវេទិកាសាធារណៈនៅមូលដ្ឋាន និងចុះជួបប្រាស្រ័យដោយផ្ទាល់ជាមួយប្រជាពលរដ្ឋតាមខ្នងផ្ទះ តាមគ្រួសារ ដើម្បីស្តាប់ក្តីកង្វល់ សំណូមពរ និងសំណើរបស់ប្រជាពលរដ្ឋ ព្រមទាំងយកចិត្តទុកដាក់ជំរុញដោះស្រាយនូវរាល់ក្តីកង្វល់ សំណូមពរ និងសំណើទាំងនោះ ដោយផ្អែកលើច្បាប់ និងបទប្បញ្ញត្តិជាធរមាន និង (៤).បានកៀរគរធនធានពីប្រភពនានា ដើម្បីចូលរួមដោះស្រាយជីវភាពប្រជាពលរដ្ឋ ក៏ដូចជាការអភិវឌ្ឍមូលដ្ឋាន។ ជាក់ស្តែង ក្រុមការងារថ្នាក់ជាតិក្រសួងអភិវឌ្ឍន៍ជនបទ បានចុះធ្វើវេទិកាសាធារណៈនៅតាមបណ្តាក្រុង ស្រុក និងឃុំ សង្កាត់ ទទួលបានសំណើ និងសំណូមពររបស់ប្រជាពលរដ្ឋសរុបចំនួន ២៦៥ករណី ក្នុងនោះក្រុមការងារបានដោះស្រាយនៅនឹងកន្លែងបានចំនួន ៩២ករណី និងនៅសេសសល់ ចំនួន ១៧៣ករណីទៀត ដែលក្រុមការងារកំពុងរិះរកនីតិវិធីដោះស្រាយបន្ត។

គួរកត់សម្គាល់ផងដែរថា ក្នុងចំណោមសំណូមពរដែលបានលើកឡើងក្នុងវេទិកាសាធារណៈនោះ

ពុំសូវមានសំណូមពរពាក់ព័ន្ធនឹងការផ្តល់សេវាសារណៈឡើយ គឺច្រើនតែសំណូមពរពាក់ព័ន្ធដល់ការងារអភិវឌ្ឍមូលដ្ឋាន។ នេះអាចសបញ្ជាក់ឲ្យឃើញថា ការផ្តល់សេវាសាធារណៈដែលផ្តល់ដោយស្ថាប័នគ្រប់សមត្ថកិច្ចដំណើរការបានល្អ និងពេញចិត្តពីសំណាក់សាធារណជន។ ចំណែកសំណូមពរពាក់ព័ន្ធនឹងការអភិវឌ្ឍ ដែលមានតម្រូវការថវិកាតិចតួច ក្រុមការងារបានដោះស្រាយនៅនឹងកន្លែង ប៉ុន្តែចំពោះសំណូមពរដែលលើសពីលទ្ធភាពដោះស្រាយនោះ ក្រុមការងារបានឆ្លើយបំភ្លឺជូនវេទិកា និងបានធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលដើម្បីស្នើសុំដាក់បញ្ចូលក្នុងគម្រោងថវិកាជាតិ។

**១.២. ស្ថានភាពមន្ត្រីរាជការ**

គិតត្រឹមដំណាច់ឆ្នាំ២០១៩នេះ ក្រសួងអភិវឌ្ឍន៍ជនបទមានមន្ត្រីរាជការក្របខណ្ឌសរុបចំនួន ១ ៧៨៨ នាក់ (ស្រីចំនួន ៤៥៥នាក់) ក្នុងនោះ នៅថ្នាក់កណ្តាលក្រសួងមានចំនួន ៦២៦នាក់ (ស្រីចំនួន ១៨៨ នាក់) ថ្នាក់មន្ទីររាជធានី ខេត្ត មានចំនួន ១ ១៦២នាក់ (ស្រីចំនួន ២៦៧នាក់)។ ក្រៅពីនេះ ក្រសួងក៏មានថ្នាក់ដឹកនាំ និងទីប្រឹក្សាដែលស្ថិតនៅក្រៅក្របខណ្ឌចំនួន ៧០នាក់ (ស្រីចំនួន ៩នាក់)។ មន្ត្រីរាជការក្នុងឆ្នាំ២០១៩ មានការថយចុះចំនួន ៤១នាក់ បើប្រៀបធៀបនឹងឆ្នាំ២០១៨ ដែលក្នុងនោះ (១). ក្របខណ្ឌផ្ទេរចូលចំនួន ១៨នាក់ (២).ផ្ទេរក្របខណ្ឌចេញចំនួន ១៥នាក់ (៣).លុបឈ្មោះចេញពីក្របខណ្ឌចំនួន ៥នាក់ និង(៤).ចូលនិវត្តន៍ចំនួន ៣៣នាក់។

**១.៣. ការបណ្តុះបណ្តាលក្នុងប្រទេស**

ក្រសួងបានរៀបចំដោយផ្ទាល់ និងបានចូលរួមជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា នូវការបណ្តុះបណ្តាលក្នុងប្រទេសចំនួន ៦៣វគ្គ ដែលក្នុងនោះ (១).វគ្គបណ្តុះបណ្តាលបានចំនួន ២១វគ្គ និង(២).សិក្ខាសាលាផ្សព្វផ្សាយបានចំនួន ៤២វគ្គ។ ទន្ទឹមនេះ ក្រសួងក៏បានបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា ដែលរៀបចំដោយក្រសួង-ស្ថាប័នផ្សេងៗ សរុបបានចំនួន ៨១៦វគ្គ ផងដែរ។

**១.៤. ការបណ្តុះបណ្តាលក្រៅប្រទេស**

ក្រសួងបានចាត់មន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសមួយចំនួនរួមមាន (១).វគ្គបណ្តុះបណ្តាលរយៈពេលខ្លី (តិចជាង៦ខែ) ចំនួន ១៣លើក ដែលមានអ្នកចូលរួមសរុបចំនួន ៣៧នាក់ (ស្រីចំនួន ០៧នាក់) (២).សិក្ខាសាលាចំនួន ១០លើក ដែលមានអ្នកចូលរួមសរុបចំនួន ៣៤នាក់ (ស្រីចំនួន ១០នាក់) (៣).ទស្សនកិច្ចសិក្សាចំនួន ០៣លើក ដែលមានអ្នកចូលរួមសរុបចំនួន ០៤នាក់ និង(៤).ការបណ្តុះបណ្តាលរយៈពេលវែង (ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសកូរ៉េ និងប្រទេសចិន) ចំនួន ០៣លើក ដែលមានអ្នកចូលរួមសរុបចំនួន ០៤នាក់ (ស្រីចំនួន ០៣នាក់)។

ជារួមក្នុងឆ្នាំ២០១៩នេះ មន្ត្រីរាជការទទួលបានការបណ្តុះបណ្តាល ក្នុងនិងក្រៅប្រទេស មានចំនួនសរុប ៦ ០៣៣នាក់ ដង (ស្រីចំនួន ១ ២០៩នាក់ ដង)។ បើប្រៀបធៀបឆ្នាំ២០១៨ កន្លងមកសិក្ខាកាមទទួលការបណ្តុះបណ្តាលមានការកើនឡើងចំនួន ១ ៦៩៧នាក់ ដង។

**១.៥.ការបណ្តុះបណ្តាលប្រជាពលរដ្ឋនៅតំបន់ជនបទ**

ក្រសួងបានរៀបចំឡើងដើម្បីធានាបាននូវការប្រកួតប្រជែងក្នុងទីផ្សារពលកម្ម សេវាកម្ម និងអាជីវកម្មខ្នាតតូចដែលមានលក្ខណៈកាន់តែបើកចំហធំទូលាយ ទាំងក្នុងតំបន់ និងនៅលើពិភពលោក ចំពោះមុខក្រសួងបានយកចិត្តទុកដាក់យ៉ាងខ្លាំង ផ្តល់អាទិភាពលើការងារចំនួន ០៤ រួមមាន (១).បណ្តុះបណ្តាល

ជំនាញវិជ្ជាជីវៈរយៈពេលខ្លីនិងមធ្យម ដើម្បីឆ្លើយតបបានទៅនឹងតម្រូវការទីផ្សារ (២).អភិវឌ្ឍន៍ជំនាញបច្ចេកទេសសម្រាប់មនុស្សគ្រប់វ័យ ដើម្បីបង្កើតឱកាសការងារនិងប្រើប្រាស់ឲ្យអស់នូវសក្តានុពល (៣).ពង្រឹងគុណភាពនៃវគ្គបណ្តុះបណ្តាល និង(៤).លើកកម្ពស់គុណតម្លៃសិក្សាស្រាវជ្រាវ និងនវានុវត្តន៍សម្រាប់បច្ចេកវិទ្យាថ្មី។

ក្នុងស្មារតីនេះ ក្រសួងបានរៀបចំកម្មវិធីបណ្តុះបណ្តាល តាមរយៈមជ្ឈមណ្ឌលទាំង១២ របស់ខ្លួន រួមមាន៖ (១).មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ (២).មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តព្រៃវែង, (៣).មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តស្វាយរៀង (៤).មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តកំពង់ចាម (៥).មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តកំពង់ស្ពឺ (៦).មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តតាកែវ (៧).មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តបាត់ដំបង (៨).មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តពោធិ៍សាត់ (៩).មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តកំពត (១០).មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តកំពង់ធំ (១១).មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តបន្ទាយមានជ័យ និង(១២).មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តសៀមរាប ដែលបានដំណើរការបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនិងរយៈពេលវែង។ ទន្ទឹមនេះ ក្រសួងបានសម្រិតសម្រាំងនូវមុខវិជ្ជាចំនួន ២៨មុខ សម្រាប់ធ្វើការបណ្តុះបណ្តាលជូនប្រជាពលរដ្ឋជនបទ រួមមាន៖ (១).ការអភិវឌ្ឍសហគមន៍ (២).បច្ចេកទេសចិញ្ចឹមមាន់ (៣).បច្ចេកទេសចិញ្ចឹមត្រី (៤).បច្ចេកទេសដាំត្រសក់ (៥).បច្ចេកទេសចិញ្ចឹមកង្កែប-អន្ទង់ (៦).បច្ចេកទេសកែច្នៃម្ហូបអាហារ (៧).បច្ចេកទេសចិញ្ចឹមទា (៨).បច្ចេកទេសផលិតសាប៊ូលាងចាន (៩).បច្ចេកទេសបណ្តុះផ្សិត (១០).បច្ចេកទេសដាំបន្លែតាមបែបទំនើបកម្ម (១១). បច្ចេកទេសចិញ្ចឹមនិងភ្ញាស់កូនមាន់ (១២).កាត់ដេរសម្លៀកបំពាក់ (១៣).អ៊ុតសក់និងកែសម្ផស្ស (១៤). កុំព្យូទ័ររដ្ឋបាល (១៥).ភាសាអង់គ្លេស (១៦).បច្ចេកទេសចិញ្ចឹមនិងព្យាបាលជ្រូក (១៧).បច្ចេកទេសធ្វើជីកំប៉ុស្ត៍ (១៨).បច្ចេកទេសចិញ្ចឹមនិងព្យាបាលមាន់ (១៩).ជួសជុលម៉ូតូគ្រប់ប្រភេទ (២០).ជួសជុលគ្រឿងម៉ាស៊ីនខ្នាតតូច (២១).ជួសជុលវិទ្យុ ម៉ាញ៉េនិងទូរទស្សន៍ (២២).ផលិតគ្រឿងសង្ហារឹមពីឬស្សី,(២៣).បច្ចេកទេសដាំដំណាំស្រូវ (២៤).បច្ចេកទេសជួសជុលនិងថែទាំអណ្តូងស្នប់ (២៥).បច្ចេកទេសដាំដំណាំគ្រួសារ (២៦).កាត់សក់បុរស (២៧).បច្ចេកទេសបណ្តុះកូនឈើនិងផ្សាំមែក និង(២៨).បច្ចេកទេសចិញ្ចឹមក្តាមថ្ម។

សរុបសេចក្តីមក ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពនិងសមត្ថភាព ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការអភិវឌ្ឍវិស័យអភិវឌ្ឍន៍ជនបទ គឺជាកត្តាគន្លឹះសម្រាប់ពង្រឹងស្ថាប័នផង និងសម្រាប់ផ្តល់នូវចំណេះជំនាញជូនដល់ប្រជាពលរដ្ឋរស់នៅតាមបណ្តាសហគមន៍ជនបទសម្រាប់ទ្រទ្រង់ជីវភាពរស់នៅក្នុងគ្រួសារផង។ ជាក់ស្តែង ក្រសួងបានរៀបចំវគ្គបណ្តុះបណ្តាលលើទិដ្ឋភាពចំនួន ០២ គឺ៖ (១).ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ដែលជាកម្លាំងស្នូលគាំទ្រដោយផ្ទាល់ដល់ការអនុវត្តផែនការជាយុទ្ធសាស្ត្ររបស់ក្រសួងផ្ទាល់ និង(២).ការបណ្តុះបណ្តាលចំណេះជំនាញដល់ប្រជាពលរដ្ឋជនបទ សម្រាប់លើកកម្ពស់ផលិតភាព និងការធ្វើពិពិធកម្មមុខរបរជាលក្ខណៈគ្រួសារ ដូចជាការសាងសង់និងថែទាំហេដ្ឋារចនាសម្ព័ន្ធជនបទ ការផ្តល់ឥណទានជនបទនិងមីក្រូហិរញ្ញវត្ថុ ការពង្រីកទីផ្សារ ការងារកសិកម្ម ការងារប្រកបសិប្បកម្ម និងសេវាកម្ម។ល។ ដើម្បីបង្កឱកាសដល់ការរកប្រាក់ចំណូលបន្ថែមផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំគ្រួសារ។

## ២. ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍

ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធ និងគមនាគមន៍ គឺជាកត្តាដ៏សំខាន់សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច ព្រមទាំងពង្រឹងការប្រកួតប្រជែង និងជំរុញពិពិធកម្មសេដ្ឋកិច្ចកម្ពុជា ជាពិសេសសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ក្នុងន័យនេះ ដើម្បីជំរុញឲ្យតំបន់ជនបទមានការរីកចម្រើនយ៉ាងឆាប់រហ័ស ក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ២០១៩-២០២៣ សម្រាប់ការតភ្ជាប់មួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ គ្របដណ្តប់លើផ្នែកគមនាគមន៍ដឹកជញ្ជូន ទឹកស្អាត និងអនាម័យជនបទ ដែលផ្តល់អត្ថប្រយោជន៍ទាំងលើវិស័យសេដ្ឋកិច្ច និងទាំងលើវិស័យសង្គមកិច្ច ក្រសួងមានប្រភពធនធានទាំងថវិកាជាតិ ថវិកាដៃគូ និងអង្គការសង្គមស៊ីវិលនានា សម្រាប់អនុវត្ត ដែលរួមមានដូចខាងក្រោម៖

### ២.១. គម្រោងដែលអនុវត្តដោយថវិកាជាតិ

**ទី១.**ការសាងសង់ស្ពានបេតុងចំនួន ១៩កន្លែង ប្រវែងសរុបចំនួន ៨៤០ម ការសាងសង់សំណង់សិល្បការ្យ ចំនួន ៤៩៤កន្លែង និងការស្ថាបនាផ្លូវជនបទ ចំនួន ១០០គម្រោង ប្រវែងសរុបចំនួន ៥១៨,១៩គម ក្នុងនោះ (១).ផ្លូវក្រាលកៅស៊ូពីរជាន់ ប្រវែង ១០១,១៦គម (២).ផ្លូវក្រាលបេតុងប្រវែង ២៩,៩១គម និង(៣).ផ្លូវក្រាលក្រួសក្រហម មានប្រវែង ៣៨៧,១២គ.ម សម្រេចបានលទ្ធផលទាន់ពេលវេលាកំណត់ មានសោភ័ណភាព និងគុណភាពល្អដែលបម្រើដល់ការប្រើប្រាស់ប្រកបដោយសក្តានុពល។

**ទី២.**ការងារថែទាំសំណង់សិល្បការ្យមានលក្ខណៈខួប សម្រេចបានចំនួន ៥៨កន្លែង ហើយការងារថែទាំផ្លូវជនបទមានលក្ខណៈខួប សម្រេចបានចំនួន ៦៨ខ្សែ ប្រវែងសរុបចំនួន ៤០៩,១៥គម ដែលក្នុងនោះ ផ្លូវក្រាលក្រួសក្រហម ប្រវែង ៣៩៥,៦៣គម និងផ្លូវក្រាលកៅស៊ូពីរជាន់ ប្រវែង ១៣,៥២គម។

ចំណែកការងារថែទាំផ្លូវជនបទមានលក្ខណៈប្រចាំរឹញ សម្រេចបានចំនួន ៣២៧ខ្សែ ប្រវែងសរុបចំនួន ២ ៨១១,២៣ គម ដែលក្នុងនោះ ផ្លូវក្រាលក្រួសក្រហម ប្រវែង ២ ២៣៣,៥៩ គម និងផ្លូវក្រាលកៅស៊ូ ប្រវែង ៥៧៧,៦៤ គម។

ការងារថែទាំទាំងពីរប្រភេទនេះបានជួយសម្រួលដល់ការធ្វើដំណើរ កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ រក្សាបានគុណភាពផ្លូវឲ្យមានអាយុកាលប្រើប្រាស់បានយូរអង្វែងជានិរន្តរ៍ ហើយជៀសវៀងបាននូវការជួសជុលធំ ដែលនាំឲ្យចំណាយថវិកាជាតិច្រើន។

**ទី៣.**អាស្រ័យដោយមានការជួសជុលបន្ទាន់ជាច្រើនកន្លែង រួមមាន ផ្លូវប្រវែង ២៨៥,១៤ គម និងលូមូលចំនួន ២៣កន្លែង លូប្រអប់បានចំនួន ១កន្លែង និងស្ពាន ចំនួន ៩កន្លែង នោះទើបនៅទូទាំងប្រទេសពុំដែលមានការដាច់ផ្លូវ បាក់ស្ពាន ដាច់លូ ដែលបង្កឲ្យមានការរាំងស្ទះចរាចរណ៍អស់រយៈពេលយូរឡើយ។ លើសពីនេះទៀត ក្រសួងបានទំនាក់ទំនង និងសហការជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ចនគរបាលចរាចរណ៍ និងអាជ្ញាធរមូលដ្ឋាន ចុះទប់ស្កាត់យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទ បានចំនួន ៥១ករណី នៅតាមបណ្តាខេត្តចំនួន ២៤។

**ទី៤.**សមិទ្ធផលដែលសម្រេចបានដោយគម្រោងសាច់ប្រាក់ពលកម្ម មិនត្រឹមតែបានផ្តល់សារៈសំខាន់យ៉ាងធំធេង ដល់ការអភិវឌ្ឍសហគមន៍នៅមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានផ្តល់ឱកាសការងារដែលបង្កលក្ខណៈឲ្យប្រជាជនមានលទ្ធភាពទទួលបាននូវប្រាក់កម្រៃបន្ថែម ទប់ស្កាត់ចំណាកស្រុក ចំណាកប្រទេស លើកកម្ពស់ជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាជនជនបទផងដែរ។

**ទី៥.**ការងារពាក់ព័ន្ធនឹងទិន្នន័យសារពើភណ្ឌផ្លូវជនបទដែលក្រសួងសម្រេចបាន រួមមាន (១).ប្រមូលទិន្នន័យផ្លូវជនបទចំនួន ៤២៤ខ្សែ ស្មើនឹង ១ ២២៩,៧គម (២).ធ្វើបច្ចុប្បន្នភាពទិន្នន័យផ្លូវជនបទចំនួន ៣៣២ខ្សែ ស្មើនឹង ២ ០៧០,៨២ គម (៣).អភិវឌ្ឍ ប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្លូវជនបទជំនាន់ ទី១ និងទី២(RRI-RRAMS) (៤).អនុវត្តសាកល្បងការប្រមូលទិន្នន័យដោយប្រើប្រាស់ Application សម្រាប់ខេត្តកំពង់ឆ្នាំង ចំនួន ១ ៦០០ គម (៥).ពិសោធន៍ និងវិភាគទិន្នន័យ ដែលប្រមូលបានតាមរយៈ App បានចំនួន ១ ៦០០ គម សម្រាប់ការកសាងផែនការថែទាំ និងជួសជុលផ្លូវជនបទ និង(៦).រៀបចំប្រព័ន្ធគ្រប់គ្រងកិច្ចសន្យាគម្រោងស្ថាបនា កែលម្អ ជួសជុល និងថែទាំផ្លូវជនបទ។

**ទី៦.**ក្រុមការងារគ្រប់គ្រងសារពើភណ្ឌផ្លូវជនបទតាមប្រព័ន្ធព័ត៌មានវិទ្យា បាននិងកំពុងសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អភិវឌ្ឍប្រព័ន្ធទិន្នន័យស្វ័យប្រវត្តិកម្មមួយ ដែលមានមុខងារសម្រាប់រៀបចំផែនការថែទាំ និងជួសជុលផ្លូវជនបទទៅតាមអាទិភាពដែលជាតម្រូវការចាំបាច់ និងសក្តានុពលនៃខ្សែផ្លូវនីមួយៗ បានរួចរាល់ប្រមាណ៨៥% ហើយគ្រោងបញ្ចប់នៅក្នុងអំឡុងខែមីនា ឆ្នាំ២០២០ ខាងមុខនេះ។ តាមរយៈការប្រើប្រាស់ប្រព័ន្ធទិន្នន័យស្វ័យប្រវត្តិកម្មនេះ គឺជាការចូលរួមចំណែកក្នុងការជំរុញការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ទំនើប ប្រកបដោយគុណភាព ដែលរួមបញ្ចូលទាំងការពង្រឹងក្របខណ្ឌគតិយុត្ត ការកសាងសមត្ថភាពស្ថាប័ន ការធ្វើទំនើបកម្មមូលដ្ឋានសម្ភារបច្ចេកទេស ការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងរដ្ឋបាលអេឡិចត្រូនិក ជាពិសេសបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការធ្វើផែនការផ្លូវជនបទកាន់តែមានភាពសុក្រឹត។

**ទី៧.**ការងារផ្គត់ផ្គង់ទឹកជនបទ ក្រសួងបានសាងសង់ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតជាច្រើនកន្លែង ដែលមានលក្ខណៈធន់នឹងការប្រែប្រួលអាកាសធាតុនៅទូទាំងប្រទេស ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ជាពិសេសនៅក្នុងអំឡុងពេលជួបគ្រោះរាំងស្ងួតនៅគ្រប់រដូវកាល។ ក្រសួងបានសាងសង់អណ្តូងទឹកស្អាតគ្រប់ប្រភេទបានចំនួន ៣ ៦០៧អណ្តូង ជួសជុលអណ្តូងទឹកដែលខូចគ្រប់ប្រភេទបានចំនួន ១ ១៥៦អណ្តូង សាងសង់និងស្តារស្រះទឹកសហគមន៍ប្រើប្រាស់បានចំនួន ២២២ស្រះ នៅតាមតំបន់ដែលពុំអាចជីកអណ្តូងបាន សាងសង់អាងត្រងទឹកភ្លៀងចំណុះ ៤ម៉ែត្រគូបបានចំនួន ៦៦អាង អាងត្រងទឹកភ្លៀងចំណុះ ១០ ០០០លីត្រ បានចំនួន ៩០៩អាង សាងសង់ពាងត្រងទឹកភ្លៀងចំណុះ ១ ០០០ លីត្រ បានចំនួន ៦០ ២៣០ពាង សាងសង់អាងចម្រោះទឹកសាធារណៈ បានចំនួន ០៤កន្លែង នៅតាមសាលារៀន សាងសង់ធុងចម្រោះទឹកពីបេតុងបានចំនួន ២១ ៣០៦ធុង សម្រាប់ចែកតាមគ្រួសារក្រីក្រ សាងសង់ប្រព័ន្ធចែកចាយទឹកស្អាតតាមទុយោជូនសហគមន៍បានចំនួន ២១៣កន្លែង សាងសង់ស្ថានីយ៍ទឹកស្អាតសម្រាប់ច្រកទឹកដាក់ក្នុងពីដុងចំណុះ ៣០លីត្រ បានចំនួន ១១កន្លែង សាងសង់ទំនប់បង្ហៀរសម្រាប់ស្រោចស្រពច្បារដំណាំបានចំនួន ២១កន្លែង និងផ្តល់ធុងដាក់ទឹកហូបចំណុះ ២០លីត្រ បានចំនួន ៧ ៥៤៧គ្រួសារ។

**ទី៨.**ការងារលើកកម្ពស់អនាម័យជនបទ ត្រូវបានទទួលការយកចិត្តទុកដាក់យ៉ាងខ្លាំង។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១៩ ការងារនេះសម្រេចបានលទ្ធផលចម្បងៗ រួមមាន៖ (១).ចុះបំផុសការសាងសង់បង្គន់អនាម័យដល់សហគមន៍តាមភូមិគោលដៅ និងវាយតម្លៃនៅក្នុងខេត្តចំនួន១២ គឺ៖ ខេត្តកែប កោះកុង ក្រចេះ ប៉ៃលិន ឧត្តរមានជ័យ សៀមរាប កំពង់ចាម កំពង់ស្ពឺ កំពង់ឆ្នាំង ស្វាយរៀង ត្បូងឃ្មុំ និងខេត្តព្រះសីហនុដែលមានប្រជាពលរដ្ឋចូលរួមសរុបចំនួន ៣ ៧៧៦គ្រួសារ (២).សាងសង់បង្គន់អនាម័យចាក់

ទឹកតាមផ្ទះឯកជនចំនួន ២៩ ៨៩៥បង្គន់ (៣).ចុះត្រួតពិនិត្យតាមដាន និងបំផុសការលើកកម្ពស់អនាម័យនៅតាមសហគមន៍ចំនួន ២៩សង្កាត់ ចំនួន០៨លើក និងនៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ចំនួន ១លើក មានប្រជាជនចូលរួមចំនួន ១ ០៥១នាក់ (៤).រៀបចំវគ្គបណ្តុះបណ្តាលមន្ត្រី ជាគ្រូបង្គោលតាមមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពត កំពង់ធំ ព្រៃវែង ស្វាយរៀង កំពង់ស្ពឺ កំពង់ឆ្នាំង តាកែវ ក្រចេះ រតនគិរី និងខេត្តព្រះវិហារ ចំនួន ៨វគ្គ ស្តីពីការគ្រប់គ្រងទិន្នន័យអនាម័យតាមរយៈការកត់ត្រានិងការគូសផែនទីអនាម័យភូមិ បច្ចេកទេសផ្ទៀងផ្ទាត់ភូមិ ODF ការប្រើប្រាស់ GPS ក្នុងការកំណត់ទីតាំងបង្គន់កើនថ្មី (៥).ចុះពិនិត្យតាមដាននិងវាយតម្លៃជាមួយអង្គការ UNICEF និង SNV លើកម្មវិធី CLTS និង SC WASH និងភូមិ ODF ចំនួន ៦លើក ក្នុងខេត្តសៀមរាប ពោធិ៍សាត់ ក្រចេះ កំពង់ស្ពឺ និងបាត់ដំបង ផ្តោតសំខាន់លើការផ្ទៀងផ្ទាត់ភូមិ ODF ការអនុវត្តកម្មវិធី CLTS និង SC WASH និងកាពិនិត្យលើការកត់ត្រាសៀវភៅភូមិ និងផែនទីអនាម័យភូមិ (៦).ផ្តល់ចានបង្គន់ដល់ប្រជាពលរដ្ឋចំនួន ៣៤២ និងសាងសង់បង្គន់ចាក់ទឹកចំនួន ២ ០១៧បង្គន់ និងបង្គន់ចាក់ផេះចំនួន ២ ០៤៣បង្គន់។

**២.២. គម្រោងសហប្រតិបត្តិការ**

ក្នុងន័យបំពេញបន្ថែមទាំងលទ្ធភាព និងសមត្ថភាពនោះ រាជរដ្ឋាភិបាលបានបើកទូលាយកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យជាមួយដៃគូអភិវឌ្ឍន៍ និងបណ្តាប្រទេសជាមិត្ត ដោយស្មើភាពស្របតាមពាក្យស្លោក "**កែទម្រង់ខាងក្នុង បង្កើនមិត្តខាងក្រៅ ក្នុងស្មារតីឯករាជ្យ**" ក្រោមរូបភាពពហុភាគី ទ្វេភាគី និងទំនាក់ទំនងជាសាធារណៈ។

**ទី១.**គម្រោងគាំទ្រដោយពហុភាគីមានសរុបចំនួន ៧គម្រោង ដែលក្នុងនោះ៖ គម្រោង ចំនួន០២ គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) រួមមាន៖ (១).គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរៈបរិស្ថាន (សម្រាប់កែលម្អផ្លូវជនបទពីក្រាលក្រួសក្រហមទៅជាផ្លូវកៅស៊ូ ឬផ្លូវបេតុង និងមានភាពធន់នឹងបម្រែបម្រួលអាកាសធាតុ មានប្រវែង ២៥០គម) (២).គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី២ (សម្រាប់ធ្វើឲ្យប្រសើរឡើងផ្នែកទឹកស្អាត និងអនាម័យជនបទ)។ គម្រោងចំនួន០២ គាំទ្រដោយធនាគារពិភពលោក (WB) រួមមាន៖(១).គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ (សម្រាប់កាត់បន្ថយភាពងាយរងគ្រោះ និងពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុនៃបណ្តាញផ្លូវជនបទនៅកម្ពុជា) និង (២). គម្រោងពិពិធកម្មវិស័យកសិកម្មកម្ពុជា (CASDP)(សម្រាប់សម្របសម្រួលខ្សែច្រវ៉ាក់តម្លៃពិពិធកម្មវិស័យកសិកម្មនៅក្នុងតំបន់ភូមិសាស្ត្រខេត្តក្រុងចំនួន ១៣ ក្នុងប្រទេសកម្ពុជា និងផ្តល់អន្តរាគមន៍ឆ្លើយតបជាបន្ទាន់ និងមានប្រសិទ្ធភាពក្នុងករណីមានវិបត្តិ និងសង្គ្រោះបន្ទាន់)។ គម្រោងចំនួន១ គាំទ្រដោយ ADB, AFD, Korea Eximbank, DFAT, GOA, NDF សម្រាប់កែលម្អផ្លូវជនបទដំហាន២ (RRIP-II) (សម្រាប់ធ្វើឲ្យមានលក្ខណៈប្រសើរឡើងនូវការធ្វើដំណើររបស់ប្រជាពលរដ្ឋរស់នៅក្នុងខេត្តគោលដៅទាំង១០ ទៅកាន់ទីផ្សារ បង្កើនឱកាសការងារ ងាយស្រួលក្នុងការទទួលសេវាសង្គម សមស្របទៅនឹងបរិបទបម្រែបម្រួលអាកាសធាតុ និងអាចឱ្យប្រជាពលរដ្ឋធ្វើដំណើរបានគ្រប់រដូវកាល)។ គម្រោងចំនួន១ គាំទ្រដោយ ADB, Korea Eximbank សម្រាប់កែលម្អផ្លូវជនបទដំហានទី៣ (RRIP-III)(សម្រាប់ធ្វើឱ្យមានលក្ខណៈប្រសើរឡើងដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ បានគ្រប់រដូវកាលក្នុងការទទួលបាននូវសេវាសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចជនបទក្នុងខេត្តគោលដៅចំនួន១០) និងគម្រោងចំនួន១ គាំទ្រដោយ IFAD សម្រាប់គាំទ្រ

និរន្តរភាពហេដ្ឋារចនាសម្ព័ន្ធជនបទដើម្បីទីផ្សារកសិករ និងពាណិជ្ជូបនីយកម្មកសិកម្ម(សម្រាប់ជំរុញកម្លាំងផលិតភាព និងអភិវឌ្ឍសហគ្រិនភាព ដើម្បីកំណើនសេដ្ឋកិច្ចជនបទ)។

កិច្ចសហប្រតិបត្តិការជាមួយសហគមន៍ប្រជាជាតិអាស៊ាន ក្រសួងបានចាត់តាំងថ្នាក់ដឹកនាំទៅចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ស្តីពីការងារអភិវឌ្ឍន៍ជនបទ និងលុបបំបាត់ភាពក្រីក្រអាស៊ាន លើកទី១១ នៅថ្ងៃទី០៤ ដល់ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅទីក្រុងណៃពិដោរ នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។ កិច្ចប្រជុំនេះបានសម្រេចទៅលើគោលការណ៍នៃកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍រួមគ្នានៅក្នុងបណ្តាប្រទេសជាសមាជិកសមាគមអាស៊ាន ជាពិសេសក្នុងវិស័យអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រ។ ជាមួយគ្នានេះ ក្រសួងក៏បានចាត់បញ្ចូលថ្នាក់ដឹកនាំទៅចូលរួមកិច្ចប្រជុំសហប្រតិបត្តិការអាស៊ានបូកបី (ចិន-ជប៉ុន-កូរ៉េ) ផងដែរ នៅសាធារណរដ្ឋប្រជាមានិតចិន នាពេលកន្លងមក។

**ទី២**-គម្រោងដែលគាំទ្រដោយទ្វេភាគី មានចំនួន ០៩ ក្នុងនោះ ០១គម្រោងគាំទ្រដោយរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាឡឺម៉ង់ គឺគម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទជំហានទី៦ (សម្រាប់ធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌរស់នៅរបស់ប្រជាពលរដ្ឋនៅទីជនបទ)។ ០១គម្រោងគាំទ្រដោយរដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌា គឺគម្រោងផ្គត់ផ្គង់ទឹកស្អាត(សម្រាប់ផ្តល់ទឹកស្អាតជូនប្រជាពលរដ្ឋនៅជនបទ)។ ០៥ គម្រោងគាំទ្រដោយសាធារណៈរដ្ឋប្រជាមានិតចិន គឺៈ (១). គម្រោងកាត់បន្ថយភាពក្រីក្រតាមរយៈការអភិវឌ្ឍសេដ្ឋកិច្ចជនបទជំហាន២ (សម្រាប់បង្កើនចំណូលប្រជាពលរដ្ឋតាមទីជនបទ តាមរយៈការធ្វើឲ្យប្រសើរឡើងនូវបរិស្ថានអាជីវកម្ម សមត្ថភាព និងសហប្រតិបត្តិការ) (២).គម្រោងកែលម្អផ្លូវជនបទជំហាន២ (សម្រាប់ធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌរស់នៅរបស់ប្រជាពលរដ្ឋនៅទីជនបទ និងចូលរួមកាត់បន្ថយភាពក្រីក្រ) (៣).គម្រោងសហប្រតិបត្តិការសាកល្បងកាត់បន្ថយភាពក្រីក្រកម្ពុជា-ចិន (សម្រាប់អនុវត្តគំនិតផ្តួចផ្តើមសហប្រតិបត្តិការកាត់បន្ថយភាពក្រីក្រ នៅអាស៊ីបូព៌ាដែលស្នើដោយរដ្ឋាភិបាលចិន និងលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរភាពក្រីក្រ រួមគ្នាកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន) និង(៤).គម្រោងស្វែងរកការគាំទ្រក្នុងការលើកកម្ពស់អនាម័យនៅជនបទ (សម្រាប់អនុវត្តគំនិតផ្តួចផ្តើមសហប្រតិបត្តិការកាត់បន្ថយភាពក្រីក្រ នៅអាស៊ីបូព៌ាដែលស្នើដោយរដ្ឋាភិបាលចិន និងលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរភាពក្រីក្រ រួមគ្នាកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន) (៥).គម្រោងមូលនិធិកិច្ចសហប្រតិបត្តិការ មេគង្គឡានឆាង ស្តីពីគម្រោងអភិវឌ្ឍន៍សហគមន៍ចម្រុះតាមដងទន្លេមេគង្គជំហានទី២ ។ ០១គម្រោងគាំទ្រដោយភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ គឺគម្រោងភាពធន់នឹងគ្រោះមហន្តរាយ និងការគ្រប់គ្រងទឹកនៅកម្ពុជា (សម្រាប់បង្កើនភាពធន់នៃសហគមន៍ដែលរងផលប៉ះពាល់ពីគ្រោះថ្នាក់ និងគ្រោះមហន្តរាយនៅក្នុងប្រទេសកម្ពុជា) និង ០១គម្រោងទៀតគឺ គម្រោងអភិវឌ្ឍន៍ជនបទដោយប្រើប្រាស់វិធីសាស្ត្រ "ចលនាភូមិថ្មី" (សម្រាប់លើកកម្ពស់កម្រិតជីវភាព កែលម្អបរិស្ថានរស់នៅ និងផ្លាស់ប្តូរផ្នត់គំនិតរបស់ប្រជាពលរដ្ឋនៅតំបន់ជនបទ) គាំទ្រដោយរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ តាមរយៈ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ។

## ២.៣. គម្រោងសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល

ក្រៅពីគម្រោងដែលមានកិច្ចសហប្រតិបត្តិការគាំទ្រជាមួយដៃគូអភិវឌ្ឍន៍ និងបណ្តាប្រទេសជាមិត្ត ក្រសួងក៏បានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ (Local NGOs) មានចំនួន ០៩ និងអង្គការ

មិនមែនរដ្ឋាភិបាលអន្តរជាតិមានចំនួន ៣៨ ផងដែរ សរុបមានចំនួន ៤៧អង្គការ ដែលបានផ្តល់កិច្ចសហការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ រួមមាន៖

ក.អង្គការមិនមែនរដ្ឋាភិបាលជាតិចំនួន ០៩ រួមមាន៖ (១).អង្គការជីវិតថ្លៃថ្នូរ (Life With Dignity) (២).ទឹកស្អាត ១០០១ (Teuk Saat 1001) (៣).ស្អាតកម្ពុជា (Clear Cambodia) (៤).អភិវឌ្ឍន៍សហគ្រាសទឹក និងអនាម័យកម្ពុជា (WaterSHED Cambodia) (៥).សមាគមសម្របសម្រួល និងអភិវឌ្ឍន៍សង្គម (Reform and Development Society Association (RDSA),(៦).អភិវឌ្ឍន៍ និងសង្គ្រោះសកលកម្ពុជា (Cambodia Global in Action (៧).សហការដើម្បីអភិវឌ្ឍន៍កម្ពុជា(Partnership for Development in Kampuchea ) (៨). អភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព(Development and Parnership in Action) (៩).សកលវិទ្យាល័យអន្តរជាតិ (International University )។

ខ.អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមានចំនួន ៣៨ រួមមាន៖ (១).អភិវឌ្ឍន៍តំបន់អាស៊ីអាគ្នេយ៍ ( Southeast Asia Development Program) (២). វើលរីញូ (World Renew ) (៣). អ្នកជិតខាងកម្ពុជា(Neighbor of Cambodia ) (៤).មូលនិធិនៃក្តីសង្ឃឹម(The Operation Hope Foundation) (៥). សហគ្រាសអភិវឌ្ឍន៍អន្តរជាតិ កម្ពុជា (International Development Enterprises Cambodia ) (៦). អេស៊ីអា/ការីតាសអូស្ត្រាលី (ACR/Caritas Australia) (៧)អង្គការ អេហ្វ អេក កម្ពុជា (FH Cambodia) (៨).គណៈកម្មាធិការមិត្តភាពមិនណូណៃថ៍(Mennonite Center Committee) (៩).ផ្លែនអន្តរជាតិកម្ពុជា (Plan International Cambodia) (១០).មូលនិធិអ៊ីសមីតវេសន៍ (East Meet West) (១១). ការីតាសកម្ពុជា (Caritas Cambodia ) (១២).សាម៉ារីតាន់ភឺស(Samaritan's Purse International Relief) (១៣). អភិវឌ្ឍន៍ធនធានអន្តរជាតិ(Resource Development International) (១៤).អាក់សិន អេតអន្តរជាតិកម្ពុជា (ActionAid International Cambodia ) (១៥).មុស្លិមអេដកម្ពុជា(Muslim Aid Cambodia ) (១៦). អភិវឌ្ឍន៍ហូឡង់(Netherland Development Organization) (១៧).ស៊ីជាប់បែលយូអេស (Church World Service) (១៨).ទស្សនៈពិភពលោកអន្តរជាតិ (World Vision International) (១៩).អង្គការ វ៉តធឺអេត(Water Aid) (២០).ចេរភាពកម្ពុជា(Sustainable Cambodia ) (២១).អង្គការហេហ្វើអន្តរជាតិ (Heifer International Cambodia) (២២).សេវដឹឈីល ឌ្រិន (Save the Children) (២៣). អង្គការឆាលហ្វានកម្ពុជា (Child Fund Cambodia ) (២៤).អង្គការ ស៊ី ប៊ី អិន កម្ពុជា(Christian Broad casting Network) (២៥).អង្គការទឹកនៃជីវិត (LifeWater)(២៦).អង្គការសម្ព័ន្ធបេសកកម្ម (Mission Alliance) (២៧). Johanniter International Assistance (JIA) (២៨).អង្គការសួនមូនិធិ (Temple Garden Foundation ) (២៩).អង្គការអាគ្រីស៊ុតអន្តរជាតិ (Agrisud International ) (៣០).អេស៊ាន អោចរីច្ឆ បម្រើកម្ពុជា (Asean Outreach Cambodia) (៣១).អង្គការអុកស្វាមនៅកម្ពុជា (Oxfam Cambodia) (៣២). The Catholic Agency For Overseas Development (CAFOD) (៣៣). កាណាន់ (World Canaan Farmer's Movement) (៣៤).Saemaul Globalization Foundation (SGF) (៣៥).People in Needs(PIN) (៣៦).World Hope International (WHP) (៣៧). Engineers Without Borders (EWB) (៣៨). Diakonia in Cabodia ។

អង្គការក្រៅរដ្ឋាភិបាលទាំងនេះ មានបេសកកម្ម ផ្តោតជាសំខាន់លើវិស័យចំនួន ០៤ ជាសំខាន់ៗ៖ (១). ការផ្គត់ផ្គង់ទឹក ការសម្អាត និងអនាម័យជនបទ មានជាអាទិ៍៖ ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ

ដល់ប្រជាជនទីជនបទឱ្យអនុវត្តទម្លាប់អនាម័យល្អ និងធ្វើការកែប្រែលម្អប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតផ្តោតទៅលើ ការជួលជុល និងការសាងសង់ប្រព័ន្ធទឹកស្អាតជាដើម (២).ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ រួមមានៈ ការបង្កើតសហគមន៍អាជីវកម្មគំរូនៅជនបទ ទីផ្សារកសិករ និងពាណិជ្ជកម្មកសិកម្ម ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ការបង្កើតប្រាក់សន្សំ ការបង្កើនប្រាក់ចំណូលគ្រួសារ និងចលនាភូមិថ្មីជាដើម (៣).ការប្រែប្រួលអាកាសធាតុ និងកសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ រួមមានៈ ការកាត់បន្ថយភាពងាយរងគ្រោះ និងការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ ការបណ្តុះបណ្តាលប្រជាជនអំពីការការប្រែប្រួលអាកាសធាតុ និងការបង្កើនភាពធន់របស់សហគមន៍ ដែលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និង (៤).ការអភិវឌ្ឍសហគមន៍ចម្រុះ រួមមានៈ ការកសាងសមត្ថភាព និងបណ្តុះបណ្តាល ដល់ប្រជាជនតាមសហគមន៍ជនបទដូចជា ការអភិវឌ្ឍកសិកម្ម ជំនាញមូលដ្ឋាន និងការអភិវឌ្ឍសហគមន៍ ផ្តល់ការបណ្តុះបណ្តាលជំនាញសម្រាប់អភិវឌ្ឍជីវភាពរស់នៅតាមរយៈ គម្រោងកសិកម្ម ការត្រៀមខ្លួនសម្រាប់គ្រោះមហន្តរាយ ការឧបត្ថម្ភកុមារកំព្រា អភិបាលកិច្ចល្អ ជំនួយស្បៀងអាហារនិងអាហារូបត្ថម្ភ។ល។

### ៣. ការកែលម្អលក្ខខណ្ឌរស់នៅ និងលើកកម្ពស់ជីវភាពរបស់សហគមន៍ជនបទ

នៅតាមតំបន់ជនបទនៃប្រទេសកម្ពុជា ប្រជាពលរដ្ឋភាគច្រើនមានទម្លាប់រស់នៅដោយពឹងផ្អែកលើការប្រើប្រាស់ធនធានធម្មជាតិ ដែលស្ថិតនៅជុំវិញសហគមន៍ឬលំនៅដ្ឋានរបស់ខ្លួនជាមធ្យោបាយសម្រាប់ប្រើប្រាស់ដល់ការរស់នៅ ដូចជា ការកាប់គម្លោធព្រៃ ឬកាប់ព្រៃធ្វើឧសដុត ការបេះស្លឹកឈើព្រៃរល្លិជាបន្លែ រកត្រី រាវខ្យង ជញ្ជាត់ត្រី បរបាញ់សត្វព្រៃ ជាដើម។ ពេលឈឺថ្កាត់ នាំគ្នាបន់ស្រន់ បញ្ចាន់អារក្ស ពឹងលើមន្តអាគមគាថា សុំសេចក្តីសុខពីម្ចាស់ទឹកម្ចាស់ដី។ល។ ការប្រើប្រាស់ទឹកត្រពាំង អូរ អណ្តូងលូ ស្ទឹងគ្មានគុណភាព ដោយមិនបានគិតអំពីផលប៉ះពាល់ដល់សុខភាពឡើយ។ ការបន្ទោបង់ពាសវាលពាសកាលនៅតាមគម្លោធព្រៃ វាលស្រែចំការ ដែលជាប្រភពនាំមេរោគហូរតាមទឹកភ្លៀងធ្លាក់ចូលទៅក្នុងប្រភពទឹក ឬចម្លងមេរោគតាមរុយ ធ្វើឲ្យកើតមានជម្ងឺរាគរុះ និងជម្ងឺដង្កាត់ផ្សេងៗជាច្រើនទៀត។ ចំពោះមុខ ក្រសួងបានខិតខំរៀបចំកម្មវិធីបណ្តុះបណ្តាលនិងផ្សព្វផ្សាយដល់ស្រទាប់ប្រជាជនគ្រប់លំដាប់ថ្នាក់ ឲ្យចេះផ្លាស់ប្តូរទម្លាប់ទាំងនេះ និងកែលម្អលក្ខខណ្ឌនៃការរស់នៅប្រកបដោយផាសុខភាព និងសុវត្ថិភាព។ ក្រសួងបានដាក់ចេញនូវចក្ខុវិស័យរយៈពេលវែង **"ឆ្នាំ២០២៥ ប្រជាពលរដ្ឋគ្រប់រូបនៅសហគមន៍ជនបទ ត្រូវមានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព"** ។ ទន្ទឹមនេះ ក្រសួងក៏បានដាក់ចេញជាគោលការណ៍សំខាន់ៗ ចំនួន ០៣ រួមមានៈ (១).ការប្រើប្រាស់បង្គន់អនាម័យឲ្យបានគ្រប់គ្នា (២).មានទម្លាប់លាងសម្អាតដៃជាមួយសាប៊ូក្រោយពេលបន្ទោបង់ និងមុនបរិភោគអាហារ និង(៣).ហូបទឹកដែលមានសុវត្ថិភាព។

**ទី១**.ចុះផ្សព្វផ្សាយណែនាំ អប់រំប្រជាជននៅតំបន់ជនបទ យល់ដឹងពីរបៀបធ្វើអនាម័យផ្ទាល់ខ្លួន បញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល (ODF) ហើយងាកមករកការបន្ទោបង់ក្នុងបង្គន់ដែលសាងសង់ឡើងតាមក្បួនខ្នាតត្រឹមត្រូវ លាងសំអាតដៃមុន និងក្រោយទទួលទានអាហារ។ ទទួលទានទឹកស្អាតដែលមានសុវត្ថិភាព រក្សាទឹកទុកប្រើប្រាស់ឱ្យបានត្រឹមត្រូវ រក្សាទឹកទុកនៅពេលជួបគ្រោះរាំងស្ងួត។ល។ ជារៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលតាមរយៈក្រសួងអភិវឌ្ឍន៍ជនបទបានចំណាយថវិកាប្រមាណជាង ០២លានដុល្លារអាមេរិក រៀបចំកម្មវិធីទិវាទឹកស្អាត និងអនាម័យនៅតាមសហគមន៍ជនបទ។ ក្រៅពីនេះ ក្រសួងក៏បានសហការជាមួយដៃគូជាច្រើនទៀតដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក អង្គការ UNICEF

គម្រោងទ្វេភាគីជាមួយប្រទេសចិន ឥណ្ឌា និងអង្គការក្រៅរដ្ឋាភិបាលចំនួន ៥៣ ទៀត រៀបចំកម្មវិធីទឹកស្អាត អនាម័យ អប់រំ បណ្តុះបណ្តាលជំនាញ កសិកម្ម និងអភិវឌ្ឍន៍សហគមន៍ចម្រុះ។ សហការលើកបដាផ្សព្វផ្សាយកម្មវិធីអនាម័យ បរិស្ថានចំនួន ៣២០ផ្ទាំង នៅតាមទីប្រជុំជន និងចុះអប់រំផ្សព្វផ្សាយការប្រើប្រាស់ទឹកស្អាតតាមសហគមន៍ចំនួន ៤៥លើក ដែលមានអ្នកចូលរួមសរុបចំនួន ១ ៣៥០នាក់ ។ អប់រំផ្សព្វផ្សាយលើកកម្ពស់អនាម័យតាមគ្រួសារ និងសហគមន៍ចំនួន ២០៧លើក មានអ្នកចូលរួមសរុបចំនួន ១៤ ៤៩០នាក់ ផ្តល់ជូនជនក្រីក្រ សិស្សានុសិស្សនៅតាមជនបទមានម៉ូតូចំនួន ៤៣គ្រឿង ពូជគោចំនួន ១០២ក្បាល និងផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រចំនួន ១ ៩៩៦នាក់។

រៀបចំឯកសារវីដេអូខ្លីៗ ស្តីពីសកម្មភាពជាតិលើកកម្ពស់ទឹកស្អាតនិងអនាម័យ និងបានចាក់ផ្សព្វផ្សាយ នៅថ្នាក់មូលដ្ឋានតាមបណ្តាស្រុកគោលដៅចំនួន ៤៥ទីតាំង ។ បានរៀបចំទិវាទឹកពិភពលោក ទិវាទឹកស្អាតដល់គ្រប់ស្រទាប់មហាជន និងភាគីពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងជនជាតិដើមភាគតិច យល់ដឹងពីការប្រើប្រាស់ទឹកស្អាត និងអនាម័យ បរិស្ថានស្អាតចំនួន ២១លើក នៅទូទាំងប្រទេស។

យោងតាមរបាយការណ៍សូចនាករទឹកស្អាត និងអនាម័យជនបទ បានបង្ហាញឃើញថា ទឹកស្អាតជនបទកើនដល់ ៥៨% និងអនាម័យកើនដល់ ៧១% នៅឆ្នាំ២០១៧ (CSES 2017) និងតាមការប៉ាន់ស្មានក្នុងឆ្នាំ២០១៩ នេះ អត្រាគ្របដណ្តប់ទឹកស្អាតបានកើនដល់ ៦៥% និងអនាម័យបានកើនដល់ ៨០%។

**ទី២**.បង្កើតសួនដាំបន្លែបានចំនួន ៧៦កន្លែង ចែកបន្ទះសូឡា ១៨៧បន្ទះ ផ្តល់ម៉ាស៊ីនបូមទឹកចំនួន ២៣គ្រឿង ចែកសៀវភៅសិក្សាដល់កូនសិស្សចំនួន ៦ ២៦៧ក្បាល បង្កើតផ្សារចល័តចំនួន ១២កន្លែង។ ផ្តល់កូនជ្រូកចំនួន ១១៣ក្បាល ផ្តល់ពូជមាន់ ទា ចំនួន ១ ៣៩៦ក្បាល ផ្តល់ទីជម្រកដល់ជនក្រីក្រចំនួន ៥២២នាក់ សង់ផ្ទះ និងសាលារៀនសម្រាប់សហគមន៍ជនបទចំនួន ១០២ខ្នង។ សង់ទំនប់បង្ហៀរចំនួន ២១កន្លែង និងសាងសង់ទីលានហាលនៅតាមបណ្តាភូមិចំនួន ៤៣៤កន្លែង។

**ទី៣**.ការអភិវឌ្ឍចម្រុះសម្រាប់សហគមន៍ជនបទ បានចូលរួមយ៉ាងសកម្មក្នុងការធ្វើឲ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅជនបទ តាមរយៈការពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ការអភិវឌ្ឍភូមិចម្រុះ ការលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ ការបណ្តុះបណ្តាលជំនាញមូលដ្ឋាន និងការបង្កើនសមត្ថភាពសហគមន៍ ដើម្បីកាត់បន្ថយគ្រោះភ័យ នៃគ្រោះមហន្តរាយក្នុងសហគមន៍។ ជាលទ្ធផល ក្នុងឆ្នាំ២០១៩នេះ ក្រសួងបានរៀបចំសិក្ខាសាលា ស្តីពីការផ្លាស់ប្តូរបទពិសោធន៍ការងារពង្រឹងសមត្ថភាព គ.អ.ភ បានចំនួន ០១លើក នៅខេត្តរតនគិរី មានសិក្ខាកាមចូលរួមចំនួន ១០៦នាក់ (ស្រីចំនួន ២២នាក់)។ រៀបចំសិក្ខាសាលាចែករំលែកចំណេះដឹង ស្តីពីគោលគំនិតនៃការអភិវឌ្ឍសហគមន៍ មានសិក្ខាកាមចូលរួមចំនួន ៩០នាក់ (ស្រីចំនួន ១៩នាក់)។ បានធ្វើការបណ្តុះបណ្តាល គ.អ.ភ ស្តីពីតួនាទីភារកិច្ចក្នុងការរៀបចំផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ និងចលនាភូមិថ្មី ចំនួន ៨៣វគ្គ មកពី ៥៧៦ភូមិ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ២ ៩២៦នាក់ (ស្រីចំនួន ៨១៥នាក់)។ ធ្វើបច្ចុប្បន្នភាព គ.អ.ភ ចំនួន ៥ ៣៥២ភូមិ ក្នុងនោះ ភូមិមានសកម្មភាពចំនួន ៤ ៧១៨ភូមិ និងភូមិគ្មានសកម្មភាពចំនួន ៧៤៦ភូមិ ភូមិមានអង្គការគាំទ្រចំនួន ៣៦ភូមិ ផ្លាស់ប្តូរសមាជិកថ្មីចំនួន ៦ ៥៧៧នាក់ នៃភូមិបច្ចុប្បន្នភាព។ ទន្ទឹមនេះ ក្រសួងក៏បានផ្តល់កូនឈើហូបផ្លែ ពូជសត្វ និងស្រះទឹកគ្រួសារដល់ភូមិគោលដៅចំនួន ០៥ នៃខេត្តត្បូងឃ្មុំ កំពង់ឆ្នាំង ស្វាយរៀង និងខេត្តព្រៃវែង រួមមាន (១).ជីកស្រះទឹកគ្រួសារទំហំ ៥មx៦មx២,៥ម ចំនួន ០៨ស្រះ ដល់ ០៨គ្រួសារ (២).ផ្តល់កូនត្រីចិញ្ចឹមចំនួន

១៤ ៩៦០ ក្បាល ជូនដល់គ្រួសារចំនួន ៧៤ (៣).ផ្តល់ពូជមាន់បានចំនួន ៦០០ ក្បាល ជូនដល់គ្រួសារចំនួន ១២០ គ្រួសារ (៤).ផ្តល់កូនឈើហូបផ្លែចម្រុះចំនួន ២៥ ០០០ ដើម ជូនដល់គ្រួសារចំនួន ៥០០ គ្រួសារ (៥).ផ្តល់កូនដូងចំនួន ៧៥០ ដើម ជូនដល់គ្រួសារចំនួន ៥០០ គ្រួសារ និង (៦).ផ្តល់កូនឈើចម្រុះចំនួន ៧០០ ដើម ជូនដល់គ្រួសារចំនួន ៥០០ គ្រួសារ។ បានបណ្តុះបណ្តាលដល់គ្រួសារសហគមន៍ស្តីពីសួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្តិ៍ចំនួន ១០ វគ្គ សិក្ខាកាមចូលរួមសរុបចំនួន ៣០០ នាក់ (ស្រីចំនួន ២០៩នាក់) ផ្តល់ពូជបន្លែចម្រុះ និងសម្ភារធ្វើរោងជីកំប៉ុស្តិ៍ចំនួន ០៤ខេត្ត រួមមាន (១).ខេត្តព្រះសីហនុ បានផ្តល់ពូជបន្លែចម្រុះចំនួន ១២០គ្រួសារ និងសម្ភារធ្វើជីកំប៉ុស្តិ៍ ចំនួន ១២០គ្រួសារ (២).ខេត្តសៀមរាប បានផ្តល់ពូជបន្លែចម្រុះចំនួន ១២០គ្រួសារ និងសម្ភារធ្វើជីកំប៉ុស្តិ៍ចំនួន ១២០គ្រួសារ (៣).ខេត្តកំពង់ស្ពឺ បានផ្តល់ពូជបន្លែចម្រុះចំនួន ១២០គ្រួសារ និងសម្ភារធ្វើជីកំប៉ុស្តិ៍ចំនួន ១២០គ្រួសារ និង (៤).ខេត្តកែប បានផ្តល់ពូជបន្លែចម្រុះចំនួន ១២០គ្រួសារ និងសម្ភារធ្វើជីកំប៉ុស្តិ៍ចំនួន ១២០គ្រួសារ។ ក្នុងនោះដែរ ក្រសួងក៏បានបណ្តុះបណ្តាលប្រជាពលរដ្ឋក្នុងសហគមន៍ស្តីពី ការបញ្ជ្រាបការយល់ដឹងស្តីពីការត្រៀមបង្ការ និងកាត់បន្ថយគ្រោះហានិភ័យ នៃគ្រោះមហន្តរាយក្នុងសហគមន៍ បានខេត្តចំនួន ០៤ ស្មើនឹង ១៣ វគ្គ មានសិក្ខាកាមចូលរួមចំនួន ៤៥៥នាក់ (ស្រីចំនួន ២០៥នាក់)។

**ទី៤.**ការងារជនជាតិដើមភាគតិច ក្រសួងបានខិតខំយកចិត្តទុកដាក់សហការជាមួយអង្គការដៃគូជាតិ និងអន្តរជាតិ រៀបចំសិក្ខាសាលាចំនួន ២លើក ស្តីពីការស្វែងយល់ពីតម្រូវការអាទិភាព សម្រាប់អភិរក្ស និងអភិវឌ្ឍជនជាតិដើមភាគតិច ដែលមានអ្នកចូលរួមប្រមាណ ៤៤៧នាក់ (ស្រីចំនួន ៣០នាក់) និងផ្សព្វផ្សាយគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច។ បានពន្លឿនការចុះកំណត់អត្តសញ្ញាណជនជាតិដើមភាគតិចបានចំនួន ០២ក្រុម សរុបមកដល់ដំណាច់ឆ្នាំ២០១៩នេះ ក្រសួងបានចុះកំណត់អត្តសញ្ញាណក្រុមជនជាតិដើមភាគតិចបានចំនួន ១៥៤ក្រុម លើ៤៥៥ក្រុម ។ បានរៀបចំប្រារព្ធទិវាជនជាតិដើមភាគតិចពិភពលោកលើកទី២៥ នៅខេត្តរតនគិរី មានអ្នកចូលរួមសរុបចំនួន ៦៧០នាក់។

## ៤. ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

គោលដៅជាយុទ្ធសាស្ត្ររបស់ក្រសួងអភិវឌ្ឍន៍ជនបទ គឺការលើកកម្ពស់ផលិតភាព និងការធ្វើពិពិធភាវូបនីយកម្មកសិកម្ម សេវាកម្ម និងសិប្បកម្មលក្ខណៈគ្រួសារនៅតំបន់ជនបទនៅទូទាំងព្រះរាជាណាចក្រកម្ពុជា តាមរយៈការពង្រីកសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់ ការប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងការប្រកបអាជីវកម្មគ្រួសារ ការផ្តល់ឥណទានជនបទនិងមីក្រូហិរញ្ញវត្ថុ ការពង្រីកទីផ្សារខ្នាតតូច និងការបណ្តុះបណ្តាលចំណេះជំនាញ។

**ទី១.**កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជនបទត្រូវបានលើកកម្ពស់ ដោយការប្រកបអាជីវកម្មលក្ខណៈគ្រួសារ ការពង្រីកសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់ ការទទួលបានការងារបន្ថែម និងទទួលបានការបណ្តុះបណ្តាលមុខជំនាញមូលដ្ឋានថ្មីៗ តាមរយៈមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់ក្រសួងទាំង១២ ដែលស្ថិតនៅតាមបណ្តាខេត្តមួយចំនួន រួមមាន៖ ខេត្តព្រៃវែង ស្វាយរៀង កំពង់ចាម កំពង់ស្ពឺ តាកែវ បាត់ដំបង ពោធិ៍សាត់ កំពត កំពង់ធំ សៀមរាប និងខេត្តបន្ទាយមានជ័យ។

**ទី២.**ក្រសួងបានរៀបចំចងក្រងសហគមន៍សន្សំប្រាក់ និងបានផ្តល់ឥណទានកម្ចីដែលមានការប្រាក់ទាបចំនួន ៣ ៩៩៣ ៨០៤ ១៣៥ រៀល ស្មើនឹង ១ ០១៧ ៦៧៦,៩៩ ដុល្លារអាមេរិក ដល់ប្រជាជន សរុបចំនួន ៤ ២៥២នាក់ ស្ថិតក្នុងភូមិគោលដៅចំនួន ២៤៤ភូមិ ១២០ឃុំ ៣២ស្រុក ក្នុងខេត្តគោលដៅចំនួន

១៥។ ក្រៅពីនេះ ក្រសួងក៏បានគាំទ្រកសិករ និងសម្របសម្រួលគាំទ្រផ្នែកបច្ចេកទេសគ្រប់គ្រងធនាគារស្រូវចំនួន ១០ ០០០គ.ក្រ និងមានសមាជិកកំពុងប្រើប្រាស់សរុបចំនួន ៨៦នាក់ (ស្រីចំនួន ៦៤នាក់) សម្រាប់ជាគុណប្រយោជន៍ដល់ពួកគាត់ប្រើប្រាស់ផងដែរ។

**ទី៣**.ដើម្បីស្វែងរកទីផ្សារការងារ ក្រសួងបានរៀបចំសិក្ខាសាលាស្តីពីការរៀបចំគម្រោងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ មានសិក្ខាកាមចូលរួមសរុប ៧៦នាក់ នៅខេត្តប៉ៃលិន។ បានរៀបចំសិក្ខាសាលាស្វែងយល់ស្តីពីទីផ្សារការងារ មានសិក្ខាកាមចូលរួមចំនួន ៥០នាក់នៅខេត្តបាត់ដំបង។ បានចុះសិក្សា និងរៀបចំទីតាំងសម្រាប់រៀបចំការតាំងពិព័រណ៌ពាណិជ្ជកម្ម ដែលមានមន្ត្រីការិយាល័យរកទីផ្សារចូលរួមចំនួន ០៨ នៅស្រុកបារាយណ៍ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។ បានចុះផ្សព្វផ្សាយ និងទំនាក់ទំនងជាមួយ អាជីវករផលិតករ ឲ្យចូលរួមតាំងពិព័រណ៌ពាណិជ្ជកម្មដែលរៀបចំធ្វើនៅទីរួមខេត្តកំពង់ធំ។ បានរៀបចំការតាំងពិព័រណ៌ផលិតផលខ្មែរ **"ភូមិខ្ញុំ ផលិតផលខ្ញុំ"** នៅខេត្តកំពង់ធំ ចំនួន ១លើក ដោយមានស្តង់ចំនួន ៨០ និងមានអ្នកចូលរួមទស្សនាប្រមាណចំនួន ៣ ៤៩៦នាក់។

ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ ពិតជាបានស្តែងចេញអំពីការលើកកម្ពស់កម្រិតជីវភាពរស់នៅប្រចាំគ្រួសាររបស់ប្រជាជនជនបទពិតប្រាកដមែន មានជាអាទិ៍៖ (១).ទទួលបានចំណេះជំនាញអាជីព (២).ទទួលបានការគាំពារផ្នែកឥណទានដែលមានការប្រាក់ទាប (៣).បង្កើតទីផ្សារនិងមុខរបរ (៤).ទទួលបានពូជសត្វពូជបន្លែគ្រប់ប្រភេទនិងឧបករណ៍ប្រើប្រាស់មួយចំនួនទៀត ។ល។

**ទី៤**.ក្រសួងខិតខំបន្ថែមទៀតលើការស្រាវជ្រាវ អភិវឌ្ឍន៍ និងផ្សព្វផ្សាយបច្ចេកវិទ្យាថ្មីៗដែលមានសក្តានុពលសម្រាប់ការដាំដុះនិងការនាំចេញទៅកាន់ទីផ្សារ ដោយប្រែក្លាយការអភិវឌ្ឍតំបន់ជនបទឱ្យមានការរីកចម្រើនយ៉ាងឆាប់រហ័ស។

## ៥. បញ្ហាប្រឈម

ទន្ទឹមនឹងទទួលបានជោគជ័យក្នុងការអនុវត្តការងារសម្រាប់ឆ្នាំ២០១៩កន្លងមកនេះ ក្រសួងក៏នៅមានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម៖

១. ការងារវិមជ្ឈការ និងវិសហមជ្ឈការក្រសួងទាមទារនូវការយកចិត្តទុកដាក់បន្ថែមដើម្បីអនុវត្តឲ្យកាន់តែមានប្រសិទ្ធភាព។

២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងគមនាគមន៍ នៅមិនទាន់ឆ្លើយតបពេញលេញទៅនឹងសេចក្តីត្រូវការនៅឡើយ ហើយការថែទាំនិងការប្រើប្រាស់ផ្លូវជនបទដែលមានស្រាប់ ក៏មិនទាន់ដោះស្រាយបានល្អដែរ។

៣. ការផ្គត់ផ្គង់វត្ថុធាតុដើមសម្រាប់សាងសង់ផ្លូវជនបទ និងសំណង់សិល្បការ្យ កំពុងចោទឡើងច្រើនជាបញ្ហា។

៤. ការប្រែប្រួលអាកាសធាតុបានធ្វើឲ្យជម្រៅទឹកក្រោមដីកាន់តែជ្រៅ បង្កការលំបាកដល់ការខួងអណ្តូងទាំងខាងបច្ចេកទេស និងខាងតម្លៃ។

៥. ការងារផ្គត់ផ្គង់ទឹកស្អាតជនបទតម្រូវឲ្យមានការសម្របសម្រួលថែមទៀត ជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ។

៦. ការបណ្តុះបណ្តាលចំណេះជំនាញដល់តំបន់ជនបទនៅមានកម្រិត។



ហ Op.ញ

## ៦. ទិសដៅការងារឆ្នាំ២០២០

ឆ្នាំ២០២០នេះ ជាឆ្នាំទី២ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ២០១៩-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ និងជាឆ្នាំទីមួយនៃការធ្វើផែនការយុទ្ធសាស្ត្រថវិកា (BSP) ០៣ឆ្នាំរំកិលនៃថវិកា វិនិយោគសាធារណៈ។ ផ្អែកលើយុទ្ធសាស្ត្រនេះ ក្រសួងបានដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្ត ដល់ក្រុមការងារ និងមន្ត្រីជំនាញក្រោមឱវាទដូចខាងក្រោម៖

១. បន្តអនុវត្តយ៉ាងសកម្មនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ឲ្យកាន់តែសកម្មសម្រាប់វិស័យអភិវឌ្ឍន៍ជនបទ ដើម្បីរួមចំណែកសម្រេចកំណើនសេដ្ឋកិច្ច ៧% និងកាត់បន្ថយភាពក្រីក្រឲ្យស្ថិតនៅក្រោមអត្រា ១០% ។

២. បន្តអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ និងអភិវឌ្ឍស្ថាប័នឲ្យបានកាន់តែប្រសើរឡើងថែមទៀត ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ក្រសួង។

៣. សិក្សាស្រាវជ្រាវបច្ចេកវិទ្យាថ្មីៗ សម្រាប់បម្រើដល់ការស្ថាបនាផ្លូវជនបទ ដែលមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

៤. ការសិក្សាគម្រោង និងការអនុវត្តការងារស្ថាបនា ថែទាំ និងជួសជុលផ្លូវជនបទ ស្ពាន និងសំណង់សិល្បការគ្រប់ប្រភេទ ត្រូវដំណើរការឲ្យបានទាន់ពេលវេលាកំណត់ ប្រកបដោយគុណភាព សោភ័ណភាព មានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងត្រូវផ្តល់អាទិភាពដល់គម្រោងដោយអនុលោមតាមភាពចាំបាច់ និងលទ្ធភាពនៃថវិកា។

៥. ជំរុញឲ្យគ្រប់អង្គភាពដែលអនុវត្តគម្រោងហិរញ្ញប្បទានផ្ទាល់ និងគម្រោងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍លើការងារស្ថាបនា ថែទាំ និងជួសជុល និងសំណង់សិល្បការគ្រប់ប្រភេទ ត្រូវមានការបញ្ជាក់គុណភាពនៃសំណាកសម្ភារ និងវត្ថុធាតុដើមពីមន្ទីរពិសោធន៍របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

៦. ដាក់ឲ្យអនុវត្តសាកល្បងនូវប្រព័ន្ធទិន្នន័យ Rural Road Asset Management System ( RRA MS ) ដែលជាបច្ចេកវិទ្យាទំនើបសម្រាប់រៀបចំផែនការថែទាំ និងជួសជុលផ្លូវជនបទ។

៧. ចុះស្រង់ទិន្នន័យផ្លូវ ស្ពាន លូ ប្រព័ន្ធផ្គត់ផ្គង់ទឹក និងបង្គន់អនាម័យនៅតាមជនបទ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការមេឲ្យមានសង្គតិភាព។

៨. ជំរុញការចុះបញ្ជីអត្តសញ្ញាណជនជាតិដើមភាគតិចឲ្យបានជាអតិបរមា។ ជំរុញការអភិវឌ្ឍជនជាតិដើមភាគតិចឲ្យបានលេចធ្លោដូចតំបន់ដទៃ ទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទាំងសេវាសាធារណៈចាំបាច់នានា ហើយអភិរក្សទំនៀមទំលាប់ប្រពៃណីល្អ ភាសានិយាយនៅក្នុងសហគមន៍នីមួយៗ។

៩. បង្កើនសេវាផ្គត់ផ្គង់ទឹកជនបទដើម្បីឆ្ពោះទៅសម្រេចឲ្យបានតាមគោលដៅ ៩០% នៅឆ្នាំ២០២៣ ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ២០១៩-២០២៣។ បន្តសម្របសម្រួលរវាងគ្រប់តួអង្គពាក់ព័ន្ធលើការងារផ្គត់ផ្គង់ទឹកតាមបណ្តាញចែកចាយ។

១០.បន្តជំរុញការងារសំអាតនិងអនាម័យជនបទ ពិសេសការងារលុបបំបាត់ការបន្ទោបង់ពាសវាលពាសកាល ដើម្បីឲ្យខេត្តគោលដៅទាំង ០៥ រួមមាន ខេត្តស្វាយរៀង កំពង់ស្ពឺ កែប កំពង់ឆ្នាំង និងព្រៃវែងឲ្យក្លាយជាខេត្ត Open Defection Free ( ODF ) នៅឆ្នាំ២០២៣។ រាជធានី និងខេត្តដទៃក្រៅពីនេះ ក៏ត្រូវខិតខំយកចិត្តទុកដាក់លើការងារនេះឲ្យបានសកម្មដែរ ដោយប្រមូលផ្តុំលើការងារអប់រំផ្សព្វផ្សាយ និងការងារសាងសង់បន្ទប់ទឹក និងបង្គន់អនាម័យ។

១១.រៀបចំធ្វើវិសោធនកម្ម ( ១ ).អនុក្រឹត្យលេខ ៥១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង

អភិវឌ្ឍន៍ជនបទ (២).អនុក្រឹត្យលេខ ១៤១ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និង(៣).អនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើង។

១២.តាក់តែងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍផ្លូវជនបទ និងធ្វើបច្ចុប្បន្នភាពបទដ្ឋានបច្ចេកទេសស្តីពីការស្ថាបនា ស្តារឡើងវិញ ថែទាំ និងជួសជុលផ្លូវជនបទនិងសំណង់សិល្បការ្យ។

១៣.ជំរុញបង្កើនសកម្មភាពសេដ្ឋកិច្ចជនបទ និងសហគ្រិនភាព ដើម្បីគាំទ្រដល់ការបង្កើនប្រាក់ចំណូលតាមគ្រួសារនីមួយៗ ចូលរួមទប់ស្កាត់ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។

១៤.ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយបណ្តាអង្គការដៃគូ វិស័យឯកជន និងបណ្តាប្រទេសជាមិត្តនានា ដើម្បីកៀរគរប្រភពធនធានហិរញ្ញវត្ថុ បច្ចេកទេស និងបច្ចេកវិទ្យាថ្មីៗ សម្រាប់ទ្រទ្រង់វិស័យអភិវឌ្ឍន៍ជនបទឲ្យមានការរីកចម្រើន។

១៥.សហប្រតិបត្តិការជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីរៀបចំបែបបទ និងវិធីសាស្ត្រនៃការបង្កើតផែនការមេសម្រាប់អភិវឌ្ឍផ្លូវថ្នល់ ការរៀបចំគម្រោងប្លង់ និងការកំណត់អាទិភាពគម្រោង។

## ៧. សេចក្តីសន្និដ្ឋាន

ក្រសួងអភិវឌ្ឍន៍ជនបទ សម្រេចបាននូវការងារស្របតាមផែនការដែលដាក់ចេញដោយរាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ២០១៩-២០២៣ ដែលរៀបចំដោយក្រសួង។ លទ្ធផលដែលសម្រេចបានខាងលើនេះ គឺអាស្រ័យដោយមានកត្តាសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម និងមានការគាំទ្រយ៉ាងពេញទំហឹងក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញនូវចក្ខុវិស័យ កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ដ៏ត្រឹមត្រូវ ច្បាស់លាស់ និងឆ្លើយតបចំគោលដៅទៅនឹងសំណូមពររបស់ប្រជាពលរដ្ឋ និងលើកកម្ពស់ឧត្តមប្រយោជន៍ជាតិ។ លទ្ធផលទាំងនេះ ក៏ឆ្លុះបញ្ចាំងនូវកិច្ចខិតខំប្រឹងប្រែង និងសាមគ្គីភាពផ្ទៃក្នុងរឹងមាំរបស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅគ្រប់ថ្នាក់ គ្រប់ផ្នែក ការគាំទ្រនិងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ និងការចូលរួមពីសំណាក់ប្រជាជនគ្រប់មជ្ឈដ្ឋានក្នុងសង្គម។ ដោយផ្អែកលើលទ្ធផលជាស្នាដៃដ៏ធំធេងខាងលើនេះ គឺមានកត្តារួមផ្សំជាច្រើនដែលបង្កនូវជំនឿជឿជាក់យ៉ាងមុតមាំថា នៅឆ្នាំ២០២០ នេះ ក្រសួងនៅតែបន្តអនុវត្តការងារជូនប្រជាជនជនបទ និងជូនជាតិមាតុភូមិកាន់តែរីកចម្រើនយ៉ាងឆាប់រហ័ស ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលអាណត្តិទី៦ នេះ។៷

**រដ្ឋមន្ត្រី**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**